**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាខេត្តកំពត**

លេខ ៤៧០ សជណ

កំពត, ថ្ងៃទី០៧ ខែ មិថុនា ឆ្នាំ២០១១

# សេចក្តីជូនដំណឹង
## ស្តីពី
## ការអនុវត្តប្រមូលពន្ធលើអចលនទ្រព្យ

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៩/៥៦២ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៩ របស់ **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ *នរោត្តម សីហមុនី* ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** ត្រាស់បង្គាប់តែងតាំងអភិបាល នៃគណៈអភិបាលខេត្តកំពត។
- បានឃើញច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០១០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/១២០៩/០២៦ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩។
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក។
- បានឃើញប្រកាសលេខ ៤៩៣ សហវ.ប្រក ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១០ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការប្រមូលពន្ធលើអចលនទ្រព្យ។
- បានឃើញសេចក្តីជូនដំណឹងលេខ០០៦ សហវ.អពដ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការអនុវត្តប្រមូលពន្ធលើអចលនទ្រព្យ។

## អភិបាលខេត្តកំពត

សូមជំរាបជូនដំណឹងដល់ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី ជាម្ចាស់អចលនទ្រព្យទាំងអស់ ដែលមានទីតាំងស្ថិតនៅក្នុងខេត្តកំពត មេត្តាជ្រាបថា ពន្ធលើអចលនទ្រព្យ ត្រូវប្រមូលចាប់ពីថ្ងៃជូនដំណឹងនេះតទៅ រហូតដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១១ និងត្រូវកំណត់លើអចលនទ្រព្យដែលស្ថិតនៅតែក្នុងភូមិសាស្រ្ត រដ្ឋបាលក្រុងកំពត ដើម្បីជាគុណប្រយោជន៍ដល់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ សំរាប់អភិវឌ្ឍមូលដ្ឋាន។

១. អចលនទ្រព្យដែលត្រូវបានលើកលែងពន្ធមានដូចខាងក្រោម ៖
- អចលនទ្រព្យដែលជាដីធ្លីកសិកម្ម
- អចលនទ្រព្យដែលជាកម្មសិទ្ធិរបស់រាជរដ្ឋាភិបាល ឬស្ថាប័នរាជរដ្ឋាភិបាល
- អចលនទ្រព្យដែលត្រូវបានរៀបចំឡើងសំរាប់គោលដៅសុទ្ធសាធខាងសាសនា និងសប្បុរសធម៌ និងគ្មានចំណែកណាមួយ ឬប្រាក់ចំណូលត្រូវបានប្រើប្រាស់ជាប្រយោជន៍ឯកជន
- អចលនទ្រព្យជាកម្មសិទ្ធិរបស់បេសកកម្មការទូត ឬកុងស៊ុលបរទេស ឬអង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា
- អចលនទ្រព្យដែលជាហេដ្ឋារចនាសម្ព័ន្ធ រួមមាន ផ្លូវ ស្ពាន ប្រព័ន្ធផលិតទឹកស្អាត ឬផលិតអគ្គិសនី ព្រលានយន្តហោះ កំពង់ផែ ស្ថានីយ៍អយស្ម័យយាន

- ផ្ទះ អគារ និងសំណង់ផ្សេងៗដែលសាងសង់លើដីធ្លីកសិកម្ម ដែលបំរើផ្ទាល់ និង ជាអចិន្ត្រៃយ៍ ដល់សកម្មភាពកសិកម្ម
- អចលនទ្រព្យដែលទទួលរងនូវការខូចខាតធ្ងន់ធ្ងរដោយករណីប្រធានសក្តិ
- ផ្ទះ អគារ និងសំណង់ដែលកំពុងត្រូវបានសាងសង់តិចជាង ៨០% (ប៉ែតសិបភាគរយ) និងមិនទាន់បានប្រើប្រាស់
- អចលនទ្រព្យដែលស្ថិតក្នុងតំបន់សេដ្ឋកិច្ចពិសេស ដែលបំរើផ្ទាល់ដល់សកម្មភាព ផលិតកម្ម។

២.ម្ចាស់អចលនទ្រព្យទាំងអស់ ទោះត្រូវជាប់ ឬមិនត្រូវជាប់ពន្ធលើអចលនទ្រព្យក្តី ត្រូវបំពេញ ព័ត៌មានអចលនទ្រព្យរបស់ខ្លួន ក្នុងទម្រង់លិខិតព័ត៌មានអចលនទ្រព្យផ្តល់ឱ្យដោយសាលាសង្កាត់ ហើយត្រូវប្រគល់អោយសាលាសង្កាត់វិញក្នុងរយៈពេលយ៉ាងយូរ ១០ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីទទួលទម្រង់លិខិតព័ត៌មានអចលនទ្រព្យនោះ។

៣.អចលនទ្រព្យដែលផ្ទុយពីចំនុច**ទី១**ខាងលើ និងមានតំលៃលើសពី១០០លានរៀល ត្រូវចុះបញ្ជីដាក់លិខិតប្រកាស និងបង់ពន្ធនៅស្នាក់ការពន្ធដារក្រុងកំពត ដែលស្ថិតនៅក្នុងភូមិសាស្ត្រដែលអចលនទ្រព្យនោះស្ថិតនៅ។

**ក.** ការចុះបញ្ជីត្រូវភ្ជាប់មកជាមួយនូវឯកសារថតចំលង ដូចខាងក្រោម ៖

- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬសំបុត្រកំណើត ឬលិខិតឆ្លងដែនសំរាប់ជនបរទេស
- សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ ឬលិខិតបញ្ជាក់ទីលំនៅ
- ប័ណ្ណសំគាល់សិទ្ធិ ឬប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឬវិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុ ដែលចេញដោយរដ្ឋបាលសុរិយោដី ឬឯកសារពាក់ព័ន្ធនឹងការកាន់កាប់អចលនទ្រព្យ ដែលបញ្ជាក់ដោយអាជ្ញាធរឃុំ-សង្កាត់ឡើងទៅ។

**ខ.** ការដាក់លិខិតប្រកាសពន្ធលើអចលនទ្រព្យ

- ត្រូវធ្វើតាមទម្រង់កំណត់ដោយរដ្ឋបាលសារពើពន្ធ ចំនួន ០២ ច្បាប់ ដែលមួយច្បាប់សំរាប់រក្សាទុកនៅរដ្ឋបាលសារពើពន្ធ និងមួយច្បាប់ទៀតសំរាប់ម្ចាស់អចលនទ្រព្យ។
- ម្ចាស់អចលនទ្រព្យត្រូវធ្វើការគណនាប្រាក់ពន្ធដោយខ្លួនឯង ដោយផ្អែកលើតំលៃអចលនទ្រព្យដែលបានកំណត់ ដោយគណៈកម្មការវាយតំលៃអចលនទ្រព្យ។

**៤.** ចំពោះម្ចាស់អចលនទ្រព្យ ដែលមានអចលនទ្រព្យច្រើន ម្ចាស់អចលនទ្រព្យ ត្រូវចុះបញ្ជី ដាក់លិខិតប្រកាស និងបង់ប្រាក់ពន្ធលើអចលនទ្រព្យដាច់ដោយឡែកៗពីគ្នា។

**៥.** ពន្ធលើអចលនទ្រព្យ ត្រូវប្រមូលប្រចាំឆ្នាំ តាមអត្រា ០,១ (សូន្យក្បៀសមួយ) ភាគរយ នៃមូលដ្ឋានគិតពន្ធ។ មូលដ្ឋានគិតពន្ធលើអចលនទ្រព្យ ត្រូវកំណត់តាមតំលៃអចលនទ្រព្យ ដែលកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងត្រូវបានអនុញ្ញាតឱ្យកាត់បន្ថយនូវទឹកប្រាក់ចំនួន ១០០លានរៀល សំរាប់អចលនទ្រព្យមួយ។ តំលៃអចលនទ្រព្យក្នុងភូមិសាស្ត្ររដ្ឋបាលនីមួយៗ ត្រូវបានផ្សព្វផ្សាយជាសាធារណៈ និងបិទផ្សាយនៅតាមគ្រប់សាលាសង្កាត់ពាក់ព័ន្ធ ស្នាក់ការពន្ធដារក្រុងកំពត និងសាខាពន្ធដារខេត្តកំពត។

**៦.** ម្ចាស់អចលនទ្រព្យ ត្រូវបង់ប្រាក់ពន្ធជាប្រាក់រៀល ដោយបង់ផ្ទាល់នៅស្នាក់ការពន្ធដារក្រុងកំពត ដែលស្ថិតក្នុងភូមិសាស្ត្រដែលអចលនទ្រព្យនោះស្ថិតនៅ។

អាស្រ័យហេតុនេះ សូមឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី ជាម្ចាស់អចលនទ្រព្យមេត្តាអញ្ជើញបំពេញព័ត៌មានអចលនទ្រព្យ ចុះបញ្ជី ដាក់លិខិតប្រកាស និងបង់ពន្ធសំរាប់ឆ្នាំ២០១១ ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ និងឱ្យបានចប់សព្វគ្រប់ត្រឹមថ្ងៃ***ទី៣០ ខែកញ្ញា ឆ្នាំ២០១១*** កុំបីខាន។

TL260511

***អភិបាលខេត្តកំពត*** សង្ឃឹម និងជឿជាក់ថា ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី ដែលជាម្ចាស់អចលនទ្រព្យទាំងអស់ ពិតជាបានយល់ និងយកចិត្តទុកដាក់ បំពេញកាតព្វកិច្ចបង់ពន្ធលើអចលនទ្រព្យ ដើម្បីរួមចំណែកក្នុងការកសាង និងអភិវឌ្ឍមូលដ្ឋានឱ្យបានល្អប្រសើរ ជាពុំខានឡើយ។

**អភិបាលខេត្ត**

**ខួយ_ឃុនហ៊ួរ**

***<u>ចំលងជូន</u>***

- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គនាយកដ្ឋានពន្ធដារ
  "<u>ដើម្បីជូនជ្រាប</u>"
- អនុគណៈកម្មការវាយតំលៃអចលនទ្រព្យខេត្ត
- សាលាក្រុងកំពត
- ក្រុមការងារអចលនទ្រព្យសង្កាត់ទាំង៥ ក្នុងក្រុងកំពត
  "<u>ដើម្បីផ្សព្វផ្សាយ និងសហការអនុវត្ត</u>"
- ស្ថានីយ៍វិទ្យុ ៩ មករា កំពត FM ជាតិ ៩៩.៧0 MHz
  "<u>ដើម្បីផ្សព្វផ្សាយ</u>"
- ឯកសារ-កាលប្បវត្តិ

T1260511